ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

លេខ ១២១៥/១៦ ក.អ.ក

រាជធានីភ្នំពេញ. ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងារ និងបង្កើនតម្លាភាពនៃការផ្តល់សេវាសាធារណៈជូនវិនិយោគិន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសូមធ្វើការណែនាំដូចតទៅ៖

- វិនិយោគិនដែលមានបំណងចង់ជួបពិភាក្សាការងារជាមួយមន្ត្រីជំនាញនៅតាមនាយកដ្ឋាននីមួយៗរបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ក្រៅពីនៅការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវចុះឈ្មោះនៅបញ្ជរច្រកចេញ-ចូលតែមួយ ដើម្បីទទួលបានប័ណ្ណសម្គាល់ភ្ញៀវ (Visitor Pass)។
- មន្ត្រីប្រចាំការនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវមានភារកិច្ចចុះឈ្មោះភ្ញៀវដែលមកជួបពិភាក្សាការងារជាមួយនឹងមន្ត្រីជំនាញនៃនាយកដ្ឋាននានា ដោយត្រូវកត់ត្រានូវកាលបរិច្ឆេទ ឈ្មោះវិនិយោគិន ឈ្មោះក្រុមហ៊ុន គោលបំណងនៃជំនួប លេខទូរស័ព្ទទំនាក់ទំនង ឈ្មោះមន្ត្រីជំនាញដែលទទួលជួប និងពេលវេលាចាប់ផ្តើម និងបញ្ចប់ជំនួប។
- វិនិយោគិនដែលមកជួបមន្ត្រីជំនាញ ត្រូវដាក់តម្កល់នូវអត្តសញ្ញាណបណ្ណ ឬប័ណ្ណបើកបរ ឬលិខិតឆ្លងដែន នៅពេលចុះឈ្មោះចូល ហើយមន្ត្រីទទួលបន្ទុកចុះឈ្មោះនឹងប្រគល់ជូនវិញនៅពេលបញ្ចប់ជំនួប
- មន្ត្រីជំនាញ មិនត្រូវបានអនុញ្ញាតឱ្យជួបជាមួយវិនិយោគិនដែលមិនមានពាក់ប័ណ្ណសម្គាល់ភ្ញៀវឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី មេត្តាជ្រាប និងអនុវត្តឱ្យបានពេញលេញតាមសេចក្តីជូនដំណឹងនេះ ដើម្បីរួមគ្នាកែលម្អការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមអរគុណ !

វិមានរដ្ឋាភិបាល វិថីព្រះស៊ីសុវត្ថិ.វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥)២៣-៩៨១ ១៧៧ ទូរសារ : (៨៥៥)២៣-៩៨១ ១៧៧
Government Palace, Sisowath Quay, Wat Phnom, Phnom Penh, Cambodia.
Tel : (855) 23-981 177, EXT 109 (Admin), EXT113(inf)